ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

**ជំនួបរវាង ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
**និង ឯកឧត្តម Nobuo KISHI អនុរដ្ឋមន្ត្រីការបរទេសជប៉ុន**
******

នៅរសៀលថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង០៣:០០ នៅទីស្តីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រសួងការបរទេសជប៉ុន ដែលដឹកនាំដោយឯកឧត្តម Nobuo KISHI អនុរដ្ឋមន្ត្រីការបរទេសជប៉ុន ក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

ជាដំបូង **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន និងបានលើកឡើងអំពីការវាយតម្លៃខ្ពស់ និងការពេញចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការរីកចម្រើនក្នុងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងកម្ពុជានិងជប៉ុន។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវអំណរគុណ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ចំពោះការចូលរួមដ៏សកម្ម និងការជួយឧបត្ថម្ភរបស់ជប៉ុន ក្នុងដំណើរការសន្តិភាព ក៏ដូចជាដំណើរការស្តារ និងអភិវឌ្ឍកម្ពុជាឡើងវិញ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវក្តីជឿជាក់ថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុននៅពេលនេះ នឹងរួមចំណែកក្នុងការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។

ឯកឧត្តម Nobuo KISHI បានជម្រាបបជូនឯកឧត្តមទេសរដ្ឋមន្ត្រី ថានេះគឺជាដំណើរទស្សនកិច្ចលើកទីមួយរបស់ឯកឧត្តមមកកាន់ព្រះរាជាណាចក្រកម្ពុជា ក្នុងឋានៈជាអនុរដ្ឋមន្ត្រីការបរទេសជប៉ុន ហើយក៏បានសម្តែងនូវក្តីរីករាយចំពោះជំនួបលើកដំបូង រវាងឯកឧត្តមជាមួយនិងឯកឧត្តមទេសរដ្ឋមន្ត្រី ។ ឯកឧត្តមក៏បានសម្តែងនូវការរីករាយចំពោះការរីកចម្រើនក្នុងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ហើយបានគូសបញ្ជាក់ថា ឯកឧត្តមនឹងខិតខំដើម្បីពង្រឹងនិងពង្រីកបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ។

ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន បានជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីថា ដើម្បីពង្រឹងនិងពង្រីកបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគី រដ្ឋាភិបាលជប៉ុនមានគម្រោងអញ្ជើញ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសជប៉ុន បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់នៅកម្ពុជា ក្នុងពេលខាងមុខនេះ។

ឯកឧត្តម **អនុរដ្ឋមន្ត្រីការបរទេសជប៉ុន** បានជំរាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីថា ការបង្កើតឡើងនូវជើងហោះហើរត្រង់រវាងប្រទេសទាំងពីរ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ បានចូលរួមចំណែកដ៏សំខាន់

ក្នុងការបង្កើនឡើងនូវភ្ញៀវទេសចរជប៉ុន ក៏ដូចជាការសំរួលការធ្វើដំណើររបស់ធុរៈកិច្ចជនជប៉ុនមកកាន់ព្រះ-រាជាណាចក្រកម្ពុជា។ ឯកឧត្តម ក៏បានគូសបញ្ជាក់ថា ដើម្បីឆ្លើយតបចំពោះការកើនឡើងនូវទេសចរជប៉ុន ភាគីជប៉ុននឹងបើកនូវការិយាល័យកុងស៊ុលរបស់ជប៉ុន នៅខេត្តសៀមរាប នៅក្នុងរវាងខែមករា ឆ្នាំ២០១៨ ខាងមុខនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវការរីករាយចំពោះការអញ្ជើញរបស់រដ្ឋាភិបាលជប៉ុនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសជប៉ុន បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់នៅកម្ពុជា ហើយឯកឧត្តមបានគូសបញ្ជាក់ថា នឹងជំរាបជូន**សម្តេចតេជោនាយករដ្ឋមន្ត្រី** អំពីការអញ្ជើញនេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានសម្តែងនូវការស្វាគមន៍ចំពោះការសម្រេចរបស់រដ្ឋាភិបាលជប៉ុន ក្នុងការបង្កើតនូវការិយាល័យកុងស៊ុលរបស់ជប៉ុនប្រចាំនៅខេត្តសៀមរាប ហើយឯកឧត្តមចាត់ទុកថាការបើកនូវការិយាល័យនេះ នឹងរួមចំណែកបន្ថែមទៀតក្នុងការបង្កើនឡើងនូវភ្ញៀវទេសចរជប៉ុនមកកាន់កម្ពុជា ក៏ដូចជាការបង្កើនឡើងនូវការផ្លាស់ប្តូរសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគទុនរវាងប្រទេសទាំងពីរ។

ឯកឧត្តម **អនុរដ្ឋមន្ត្រីការបរទេសជប៉ុន** ក៏បានជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី អំពីគម្រោងរបស់រដ្ឋាភិបាលជប៉ុនក្នុងការរៀបចំទិវាភាពយន្តរបស់ជប៉ុននៅកម្ពុជា ក្នុងពេលខាងមុខនេះ ហើយបានស្នើសុំការជួយសម្រួលនិងការគាំទ្ររបស់អាជ្ញាធរពាក់ព័ន្ធរបស់កម្ពុជាចំពោះការរៀបចំនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូការស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលជប៉ុន ក្នុងការរៀបចំទិវាភាពយន្តរបស់ជប៉ុននៅកម្ពុជា ដែលនឹងរួមចំណែកដ៏សំខាន់ក្នុងការបង្កើនថែមទៀតនូវទំនាក់ទំនងរវាងប្រជាជន និងកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌រវាងប្រទេសទាំងពីរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានជម្រាបជូនឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន អំពីការរីករាយពេញចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការការកើនឡើងយ៉ាងឆាប់រហ័សនូវទំនាក់ទំនងផ្នែកសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ពិសេសគឺការកើនឡើងនូវវិនិយោគទុនរបស់ជប៉ុននៅកម្ពុជាពីចំនួន ៥៩លានដុល្លារ ក្នុងឆ្នាំ២០១៥ មកដល់ចំនួន ៨០០ លានដុល្លារ ក្នុងឆ្នាំ២០១៦ ហើយនិងការកើនឡើងនូវការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ពីចំនួនប្រមាណ៩៩៤លានដុល្លាក្នុងឆ្នាំ២០១៥ មកដល់ចំនួនប្រមាណ ១.៣៥៥ លានដុល្លារ ក្នុងឆ្នាំ ២០១៦កន្លងមកនេះ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសជប៉ុន ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាផងដែរ អំពីកិច្ចសហប្រតិបត្តិការរវាងអាស៊ាននិងជប៉ុន ហើយនិងបញ្ហាតំបន់ និងបញ្ហាអន្តរជាតិមួយចំនួនដែលភាគីទាំងពីរមានការចាប់អារម្មណ៍។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១៧